# គោលការណ៍មូលដ្ឋាន
# នៃ
# ក្រមនីតិវិធីរដ្ឋប្បវេណី

( ដោយចៅក្រមៈ យូរ ឧត្តរា )

បណ្ណាល័យច្បាប់-Law Library

( lawlibrarysite.wordpress.com )

2013

រាជបណ្ឌិត្យសភាវិជ្ជាជីវៈតុលាការ

# វគ្គ

# នីតិវិធីរដ្ឋប្បវេណី

## មេរៀន :គោលការណ៍មូលដ្ឋាននៃក្រមនីតិវិធីរដ្ឋប្បវេណី

ដោយ : លោកចៅក្រម យូរ ឧត្តរា

Received
June 25, 2013

## គោលការណ៍មូលដ្ឋាន

I-គោលការណ៍មូលដ្ឋានដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ:

១. ឯករាជភាពរបស់តុលាការ និង ការធានាមុខងាររបស់ចៅក្រម

២. គោលការណ៍នៃការជម្រះក្តីតាមច្បាប់

II- គោលការណ៍មូលដ្ឋាននៃក្រមនីតិវិធីរដ្ឋប្បវេណី

១- ការធានានូវសិទ្ធិទាមទារសវនាការ

២- គោលការណ៍ចំពោះមុខ

៣- ការទទួលខុសត្រូវរបស់តុលាការនិងភាគី

៤- ការចូលរួមរបស់តំណាងអយ្យការ

៥- គោលការណ៍ផ្សេងៗទៀតនៃការជម្រះក្តី

## I-គោលការណ៍មូលដ្ឋានដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ:

### ១. ឯករាជភាពរបស់តុលាការ និង ការធានាមុខងាររបស់ចៅក្រម

តាមមាត្រា ១២៨ ថ្មី នៃរដ្ឋធម្មនុញ្ញឆ្នាំ ១៩៩៣ ចែងថា អំណាចតុលាការ គឺជាអំណាចឯករាជ្យ ហើយមាត្រា ១៣២ ថ្មី ចែងថា

ព្រះមហាក្សត្រទ្រង់ជាអ្នកធានាឯករាជ្យនៃអំណាចតុលាការ។

ដោយសារការដោះស្រាយបណ្តឹងរដ្ឋប្បវេណី គឺជាមុខងាររបស់អង្គតុលាការ (មាត្រា ១២៨ថ្មី កថាខ័ណ្ឌទី៣នៃរដ្ឋធម្មនុញ្ញ) ចៅក្រមគឺជាអ្នកដើរតួយ៉ាងសំខាន់នៅក្នុងតុលាការ ត្រូវអនុវត្តសិទ្ធិអំណាចរបស់ខ្លួនដោយឯករាជ្យពីការអន្តរាគមន៍នានាពីសំណាក់អាជ្ញាធរ។

លើសពីនេះទៀត ចៅក្រមទទួលនូវការធានានៅក្នុងមុខងាររបស់ខ្លួន គឺមិនអាចត្រូវគេដកមុខងារបានទេ លើកលែងតែករណីមានកំហុស ឬប្រព្រឹត្តបទល្មើស ហើយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមគឺជាអ្នកសម្រេចដាក់វិន័យ(មាត្រា១៣៣ថ្មីនៃរដ្ឋធម្មនុញ្ញ)។

ដូច្នេះ ឯករាជភាពនៃអង្គតុលាការ និង ការធានា
នៅក្នុងមុខងាររបស់ចៅក្រម គឺជាផ្នែកមួយនៃ
គោលការណ៍មូលដ្ឋាននានានៃនីតិវិធីរដ្ឋប្បវេណី
ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ។

២. គោលការណ៍នៃការជម្រះក្តី

តាមមាត្រា ១២៩ថ្មីនៃរដ្ឋធម្មនុញ្ញ ចែងថា

ការជម្រះក្តីផ្តល់យុត្តិធម៌ ត្រូវធ្វើក្នុងនាមប្រជារាស្ត្រ
ខ្មែរ តាមនីតិវិធី និង ច្បាប់ជាធរមាន។ ត្រង់នេះ
មានន័យថា ការជម្រះក្តីត្រូវឡើងតាមច្បាប់ដែល
អនុម័តដោយរដ្ឋសភា ដែលជាតំណាងរបស់ប្រជា
ពលរដ្ឋកម្ពុជា ដែលជាម្ចាស់នៃប្រទេសកម្ពុជា
ហើយការជម្រះក្តីមិនត្រូវធ្វើតាមទំនើងចិត្តរបស់
ចៅក្រមឡើយ។

ហេតុនេះហើយ អាចបកស្រាយបានថា នីតិវិធីនៃការជម្រះក្តីក៏ត្រូវធ្វើឡើងតាមច្បាប់ដែរ។ ដោយសារគោលការណ៍នៃការជម្រះក្តីតាមច្បាប់ត្រូវយកទៅអនុវត្តនៅក្នុងនីតិវិធីរដ្ឋប្បវេណី គោលការណ៍នេះក៏ត្រូវបានចាត់ទុកថា ជាគោលការណ៍មូលដ្ឋានមួយនៃនីតិវិធីរដ្ឋប្បវេណីដែល

មានចែងក្នុងរដ្ឋធម្មនុញ្ញផងដែរ។ ហេតុនេះហើយ ទើបក្រមនីតិវិធីរដ្ឋប្បវេណីត្រូវបានអនុម័តឡើងទៅតាមតម្រូវការរបស់រដ្ឋធម្មនុញ្ញ។

ដូច្នេះអ្វីៗដែលបានរៀបរាប់មកនេះ គឺជាគោលការណ៍មូលដ្ឋានមួយនៃក្រមនីតិវិធីរដ្ឋប្បវេណីដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ។

បន្ទាប់មកនេះ គឺជា គោលការណ៍មូលដ្ឋានមួយៗខានៅក្នុងក្រមនីតិវិធីរដ្ឋប្បវេណី។

## II- គោលការណ៍មូលដ្ឋាននៃក្រមនីតិវិធីរដ្ឋប្បវេណី

***គោលបំណងនៃបណ្តឹងរដ្ឋប្បវេណី : មាត្រា ២ កថាខ័ណ្ឌ ១***

១-បណ្តឹងរដ្ឋប្បវេណី មានគោលបំណងឱ្យតុលាការដោះស្រាយវិវាទផ្នែករដ្ឋប្បវេណី ដោយផ្អែកលើច្បាប់ ដើម្បីការពារសិទ្ធិបុគ្គលឯកជន ។

***ការធានានូវសិទ្ធិពឹងពាក់តុលាការ: មាត្រា ២ កថាខ័ណ្ឌ ២***

២ - ជនគ្រប់រូបត្រូវបានធានានូវសិទ្ធិពឹងពាក់តុលាការចំពោះវិវាទផ្នែករដ្ឋប្បវេណី ។

***ការធានានូវសិទ្ធិទាមទារឱ្យធ្វើការសាកសួរ: មាត្រា ៣ កថាខ័ណ្ឌ ១***

១-ភាគីណាក៏មិនអាចត្រូវបានជម្រះក្តីដោយមិនបានសាកសួរ ឬ កោះហៅឡើយ ។

### ❖ គោលការណ៍ចំពោះមុខ មាត្រា ៣ កថាខ័ណ្ឌ ២

២-ក្នុងករណីណាក៏ដោយ តុលាការត្រូវគោរពគោលការណ៍ចំពោះមុខ។

### ❖ វចនាសម្ព័ន្ធនៃតុលាការ មាត្រា ២៣-២៥

– កំណត់ពីសមាសភាពនៃក្រុមប្រឹក្សាជំនុំជំរះនៅសាលាដំបូង ។

### ❖ គោលការណ៍ជំរះក្ដីជាសាធារណៈ មាត្រា ១១៥

**ការទាញហេតុផលដោយផ្ទាល់មាត់ត្រូវធ្វើឡើងនៅសាលសវនាការជាសាធារណៈ ។** ប៉ុន្តែបញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលភាពជាសាធារណៈនេះ បណ្ដាលឱ្យខូចសណ្ដាប់ធ្នាប់សាធារណៈ ឬ ករណីដែលមានបញ្ញត្តិពិសេសនៅក្នុងច្បាប់ ។

### ❖ គោលការណ៍ជ្រើសតាំងចៅក្រមទទួលបន្ទុក មាត្រា ២៦— កថាខ័ណ្ឌ ២

២-រឿងក្ដីនីមួយៗត្រូវបានបែងចែកឱ្យចៅក្រមម្នាក់ៗទទួលបន្ទុកជាស្វ័យប្រវត្ត ...

### ❖ គោលការណ៍នៃសិទ្ធិចាត់ចែង

✓ ប្រព័ន្ធបណ្ដឹងរដ្ឋប្បវេណី គឺជាប្រព័ន្ធរបស់រដ្ឋដែលជាមធ្យោបាយមួយសម្រាប់សង្គ្រោះជាចុងក្រោយនៅក្នុងករណីដែល ភាគីទាំងសង្ខាងពុំអាចឈានទៅរកដំណោះស្រាយបាន នៅក្នុងការវិវាទគ្នានោះ ។ ក្នុងករណីនេះតម្រូវឱ្យមានការដោះស្រាយវិវាទរដ្ឋប្បវេណីនោះដោយបង្ខំនៅក្នុងនាមការអនុវត្តសិទ្ធិនៃការសម្រេចសេចក្ដីរបស់រដ្ឋ ។ ប៉ុន្តែ ទោះបីជាប្រព័ន្ធរបស់រដ្ឋក៏ដោយ ក៏មានចំណុចជាច្រើនដែលត្រូវឆ្លុះបញ្ចាំងឱ្យឃើញនូវឆន្ទៈរបស់ភាគីនៅក្នុងនីតិវិធីរដ្ឋប្បវេណីនោះដែរ ។ គោលការណ៍ទាំងនោះគឺ

✓ គ្មានបណ្ដឹង = គ្មានសេចក្ដីសម្រេច ។

✓ សិទ្ធិក្នុងការធ្វើបណ្ដឹងជាសិទ្ធិឯកជនរបស់ភាគី ។

✓ **មាត្រា ១៨២: (ចំណុចដែលត្រូវវិនិច្ឆ័យដោយសាលក្រម)**

**១ តុលាការត្រូវចេញសាលក្រមចំពោះការទាមទារទាំងអស់ដែលភាគីបានសុំ ។**

**២ តុលាការមិនអាចចេញសាលក្រមចំពោះចំណុចណាដែលភាគីមិនបានសុំឡើយ ។**

✓ មាត្រា ២១៧ : ការដកពាក្យបណ្ដឹង , មាត្រា ២២០ : ការផ្សះផ្សាលើបណ្ដឹង

មាត្រា ២២១ : ការលះបង់ ឬ ការទទួលស្គាល់នូវការទាមទារ ។

សូមចូលលំអិតដូចតទៅ:

# ដំណាក់កាលនៃការចាប់ផ្ដើមបណ្ដឹង

ឧទាហរណ៍: ដើម្បីឱ្យប្រព័ន្ធបណ្ដឹងរដ្ឋប្បវេណីមានចលនាឡើង លុះត្រាតែមានភាគីម្ខាងចុចគន្លឹះ ។ នោះគឺជាការដាក់ពាក្យបណ្ដឹង ។

ការដាក់ពាក្យបណ្ដឹងនេះគឺជាសកម្មភាពជាក់ស្ដែងក្នុងការប្ដឹងទៅតុលាការដោយផ្អែកលើឆន្ទៈរបស់ភាគីនោះ ។ មានន័យថា

- គ្មានបណ្តឹង = គ្មានសេចក្តីសម្រេច ។

ភាគីម្ខាងដែលត្រូវបានគេប្តឹងហៅថាចុងចម្លើយដែលត្រូវស្ថិតក្នុងជំហរមួយត្រូវឆ្លើយតបនឹងនីតិវិធីនៃបណ្តឹងនោះ ។

- សិទ្ធិក្នុងការធ្វើបណ្តឹងគឺជាសិទ្ធិឯកជនរបស់ភាគី ។

## តើនៅក្នុងពាក្យបណ្តឹងដើមចោទចង់បានអ្វី ?

- **មាត្រា ១៨២: ( ចំណុចដែលត្រូវវិនិច្ឆ័យដោយសាលក្រម)**

**១- តុលាការត្រូវចេញសាលក្រមចំពោះការទាមទារទាំងអស់ដែលភាគីបានសុំ ។**

**២ -តុលាការមិនអាចចេញសាលក្រមចំពោះចំណុចណាដែលភាគីមិនបានសុំឡើយ ។**

ម្យ៉ាងទៀត ការបញ្ឈប់បណ្តឹងពាក់កណ្តាលទីក៏ជាការសម្រេច

តាមឆន្ទៈរបស់ភាគីដែរ ។

មាត្រា ២១៧ : ការដកពាក្យបណ្តឹង .

មាត្រា ២២០ : ការផ្សះផ្សាលើបណ្តឹង

មាត្រា ២២១ : ការលះបង់ ឬការទទួលស្គាល់នូវការទាមទារ

### ❖ *គោលការណ៍នៃការទាញហេតុផល*

**មាត្រា ៩៥ :តុលាការមិនអាចយកអង្គហេតុណា ដែលភាគីណាមួយមិនបានអះអាង មកធ្វើជាមូលដ្ឋាននៃសាលក្រមបានឡើយ ។**

**មាត្រា ១២៣ កថាខ័ណ្ឌ២:**

**អង្គហេតុដែលភាគីបានសារភាពនៅចំពោះមុខ តុលាការ និងអង្គហេតុដែលតុលាការ យល់ឃើញថា មានភាពជាក់ ស្តែង តុលាការពុំ ចាំបាច់ទទួលស្គាល់អង្គហេតុនោះដោយផ្អែកលើភស្តុតាងទេ ។**



❖ *គោលការណ៍នៃការចូលរួមរបស់ព្រះរាជអាជ្ញា*　　*មាត្រា ៦*

**១-ក្នុងករណីដែលយល់ឃើញថា ចាំបាច់ត្រូវការពារផលប្រយោជន៍សាធារណៈ តុលាការត្រូវ ជូនដំណឹងទៅតំណាង អយ្យការថា ពាក្យបណ្ដឹងត្រូវបានទទួល ។**

**២-ទោះបីជាគ្មានការជូនដំណឹងដែលបានកំណត់នៅក្នុងកថាខ័ណ្ឌទី១ខាងលើនេះក៏ដោយ ក៏តំណាងអយ្យការអាចចូលរួមក្នុងនីតិវិធីនៃបណ្ដឹងរដ្ឋប្បវេណី និងបញ្ចេញយោបល់បានដែរ ប្រសិនបើខ្លួនយល់ឃើញថា ចាំបាច់ត្រូវការពារផលប្រយោជន៍សាធារណៈ ។**

ទាំងនេះគឺជាគោលការណ៍មូលដ្ឋានជាសង្ខេបដែលមាននៅក្នុងក្រមនីតិវិធីរដ្ឋប្បវេណី។ ឥឡូវយើងចូលលំអិតតាមគោលការណ៍នីមួយៗ។



## ១- ការធានានូវសិទ្ធិទាមទារសវនាការ

ដោយសារថា ភាគីនៃបណ្ដឹងរដ្ឋប្បវេណី ត្រូវអនុវត្តតាមសេចក្ដីសម្រេចរបស់តុលាការ ហេតុនេះហើយ ប្រសិនបើសេចក្ដីសម្រេចនោះមិនមានភាពត្រឹមត្រូវទេ វាអាចនឹងបំពានលើសិទ្ធិរបស់បុគ្គលឯកជន ដោយមិនសមហេតុផល ។

ដូច្នេះទើបក្រមនីតិវិធីរដ្ឋប្បវេណី ផ្តល់ការធានា ដល់សិទ្ធិនីតិវិធីយ៉ាងច្រើនរបស់ភាគីនៃបណ្តឹងរដ្ឋប្បវេណី ដើម្បីឲ្យពួកគេអាចចូលរួមនៅក្នុងដំណើរការរឿងក្តី និង អាចការពារផលប្រយោជន៍របស់ខ្លួនបាន ។ សិទ្ធិដែលមានសារៈសំខាន់ជាមូលដ្ឋាន នៅក្នុងចំណោមសិទ្ធិនីតិវិធីនានា

ទាំងនោះ អាចហៅជារួមថា "**សិទ្ធិមូលដ្ឋាននៃនីតិវិធី**"។

ក្នុងចំណោមសិទ្ធិមូលដ្ឋាននៃនីតិវិធី ដែលមានចែងក្នុងក្រមនីតិវិធីរដ្ឋប្បវេណី សិទ្ធិនីតិវិធីដែលសំខាន់ជាងគេបំផុត គឺ សិទ្ធិទាមទារឲ្យសាកសួរ។ សិទ្ធិទាមទាមឲ្យសាកសួរ គឺជាសិទ្ធិទាមទារឲ្យមានការធានានូវឱកាសក្នុងការ

បញ្ចេញមតិយោបល់របស់ខ្លួនដែលពាក់ព័ន្ធទៅ

នឹងបញ្ហាដែលត្រូវសម្រេចសេចក្ដីដោយ

តុលាការនៅក្នុងនីតិវិធីរដ្ឋប្បវេណី និង នៅក្នុង

ការឆ្លើយតបទៅនឹងមតិយោបល់របស់ភាគីម្ខាង
ទៀត។

រដ្ឋត្រូវបង្កើតឲ្យមាននូវនីតិវិធីរដ្ឋប្បវេណី

ដែលធានានូវឱកាសបែបនេះដល់ភាគី។

ជាគោលការណ៍ ឱកាសក្នុងការបញ្ចេញមតិ

យោបល់របស់ខ្លួន និង ឱកាសក្នុងការឆ្លើយ

តបទៅនឹងយោបល់របស់ភាគីម្ខាងទៀត ត្រូវ

តែផ្ដល់ឲ្យភាគីនៅមុនការសម្រេចសេចក្ដី
(មាត្រា ៣ កថាខ័ណ្ឌទី ១)

*ការធានានូវសិទ្ធិទាមទារឱ្យធ្វើការសាកសួរៈ មាត្រា ៣ កថាខ័ណ្ឌ ១*

១-ភាគីណាក៏មិនអាចត្រូវបានជម្រះក្ដីដោយមិនបានសាកសួរ ឬ កោះហៅឡើយ ។

ប៉ុន្តែក្នុងករណីពិសេសបន្ទាន់ ការសម្រេចសេចក្តីអាចត្រូវធ្វើឡើងជាមុន ហើយក្រោយមកទើបអនុញ្ញាតឲ្យស្តាប់យោបល់របស់ភាគីដែលបានទទួលរងនូវការខូចខាតផលប្រយោជន៍ដោយសារការសម្រេចសេចក្តីបែបនេះ បាន (មាត្រា ៣២៣-១ និង មាត្រា៥៤៨-៤ វាក្យ២)។

២- គោលការណ៍ចំពោះមុខ

ដើម្បីធានានូវសិទ្ធិទាមទារឲ្យសាកសួរមានប្រសិទ្ធិភាព ការជម្រះក្តីត្រូវតែធ្វើឡើងដោយការកោះហៅភាគីទាំងសងខាងឲ្យមកបង្ហាញខ្លួននៅកាលបរិច្ឆេទតែមួយ ហើយត្រូវឲ្យភាគីប្រឈមមុខដាក់គ្នាដោយផ្ទាល់។

ប្រសិនបើអនុញ្ញាតឲ្យតុលាការកោះហៅភាគី តែម្ខាង ហើយស្តាប់ការអះអាងរបស់ភាគីនោះ ដោយពុំមានវត្តមានរបស់ភាគីម្ខាងទៀត នោះ អាចនឹងប៉ះពាល់ដល់ទំនុកចិត្តរបស់ភាគីទៅ លើភាពយុត្តិធម៌នៃការវិនិច្ឆ័យ។

ហេតុនេះហើយបានជាមានបញ្ញត្តិចែងថា ជាគោលការណ៍ តុលាការត្រូវវិនិច្ឆ័យ ដោយ គោរពគោលការណ៍ចំពោះមុខ ពោលគឺត្រូវកោះ ហៅ ភាគីទាំងសងខាង ឲ្យភាគីទាំងសងខាង ថ្លែងអំពីអំណះអំណាងរបស់ខ្លួន និង ជជែក តតាំងគ្នាទៅវិញទៅមក (មាត្រា ៣-២)។

ចំពោះគោលការណ៍ចំពោះមុខនេះ ក៏មានករណី លើកលែងមួយចំនួនដែរ ( ដូចជា មាត្រា ២០០ មាត្រា ២០១ មាត្រា ៣២៣-១ ជាដើម។

៣- ការទទួលខុសត្រូវរបស់តុលាការនិងភាគី

ការជំនុំជម្រះលើបណ្តឹងរដ្ឋប្បវេណី ត្រូវប្រព្រឹត្ត ឡើងដោយសហការគ្នារវាង តុលាការ និង ភាគី ទាំងសងខាង ដែលជាប្រធាននៃបណ្តឹងដោយ

ផ្អែកលើការបែងចែកតួនាទីរៀងៗខ្លួន។

បើពន្យល់ត្រួសៗទៅ ក្រមនីតិវិធីរដ្ឋប្បវេណី ចែងអំពីការបែងចែកតួនាទី ឬក៏ហៅម្យ៉ាងទៀត ថា សិទ្ធិអំណាច និង ការទទួលខុសត្រូវដែល បានកំណត់ដូចតទៅនេះ :

ការគ្រប់គ្រងនីតិវិធី ការដឹកនាំនីតិវិធីឲ្យ ដើរទៅមុខ ព្រមទាំងការចាត់ចែង និង

ការរៀបចំការជំនុំជម្រះ គឺជាសិទ្ធិអំណាចនិង

ការទទួលខុសត្រូវចម្បង របស់តុលាការ។

ដោយឡែក ការកំណត់នូវចំណុចដែលជាកម្មវត្ថុ

នៃការជំនុំជម្រះ និង ចំណុចនៃការសម្រេចសេច

ក្ដី ការបំភ្លឺអង្គហេតុនៃរឿងក្ដី និង ការផ្ដល់ឯក

សារដែលជាមូលដ្ឋានសម្រាប់ការសម្រេចសេច
ក្ដី គឺជាសិទ្ធិអំណាចនិងការទទួលខុសត្រូវរបស់
ភាគី។

## ៣-១. ការដឹកនាំនីតិវិធី ការចាត់ចែងនិង ការរៀបចំការជំនុំជម្រះ

ក. ដូចពន្យល់ខាងលើ ការគ្រប់គ្រង ការដឹក

នាំនីតិវិធីឲ្យដើរទៅមុខ ព្រមទាំងការចាត់ចែង

និង ការរៀចចំការជំនុំជម្រះ គឺជាសិទ្ធិអំណាច

និងការទទួលខុសត្រូវរបស់តុលាការ។

ដូច្នេះតុលាការត្រូវប្រឹងប្រែងធានាឲ្យបានថា

រឿងក្ដីរដ្ឋប្បវេណីត្រូវប្រព្រឹត្តទ្បើងដោយមាន ភាពយុត្តិធម៌ និង ឆាប់រហ័ស (មាត្រា ៤)។ នេះគឺជាកាតព្វកិច្ចចំបងរបស់តុលាការ។ សិទ្ធិអំណាចនៃការគ្រប់គ្រងលើនីតិវិធីដែលបានផ្ដល់ឲ្យតុលាការនេះ គេហៅថា សិទ្ធិអំណាចក្នុងការដឹកនាំនីតិវិធីនៃបណ្ដឹង (មាត្រា៨៩)។

ខ. ជាគោលការណ៍ សិទ្ធិអំណាចក្នុងការដឹកនាំនីតិវិធីនៃបណ្ដឹងគឺជាសិទ្ធិអំណាចរបស់តុលាការ ហើយត្រូវអនុវត្តដោយតុលាការ ( ឧទាហរណ៍: មាត្រា ៩០ មាត្រា ៩៤ មាត្រា ៩៩ និងមាត្រា ១០០ ជាដើម។

គ. ខ្លឹមសារនៃសិទ្ធិអំណាចក្នុងការដឹកនាំនីតិ

វិធីនៃបណ្តឹង មានវិសាលភាពគ្របដណ្តប់ទៅ

លើដំណើរការទាំងមូលនៃការជំនុំជម្រះ មាន

ដូចជា:

- ការកំណត់ និង ការប្តូរកាលបរិច្ឆេទ

( មាត្រា ១១៣ មាត្រា ២៤០-១ មាត្រា ២៤១ ជាដើម)

-ការសម្រេចអំពីការពន្យាអំឡុងពេល

(មាត្រា ៧៨ មាត្រា ២៤៤ ជាដើម) ដែលជា

បញ្ហាទាក់ទងនឹងដំណើរការទាំងស្រុងនៃនីតិវិធី។

- ការរៀបចំនិង ការចាត់ចែងសកម្មភាពរបស់

ភាគីនៅកាលបរិច្ឆេទដែលបានកំណត់ ( មាត្រា

៨៩ មាត្រា ១៣៨ -៦ មាត្រា ១៣៩-៣ ជាដើម)

- ការបំបែកនិងការបញ្ចូលរឿងក្តី(មាត្រា ៩៩)

- ការលើកចោលនូវមធ្យោបាយតទល់ ឬ

ការពារខ្លួនដែលដាក់ឃើតយ៉ាងមិនត្រូវនឹងពេលវេលាសមរម្យ (មាត្រា ៩៤)។

**៣-១. ការទទួលខុសត្រូវរបស់ភាគី**

-សិទ្ធិចាត់ចែងរបស់ភាគី

ក. ការសម្រេចអំពីកម្មវត្ថុ និង ទំហំនៃការជំនុំជម្រះ និងការសម្រេចលើ

កម្មវត្ថុនៃការជំនុំជម្រះនិងការចេញសាលក្រមនៅក្នុងបណ្តឹង គឺជាការទាមទារតាមផ្លូវបណ្តឹងដែលបានធ្វើឡើងដោយដើមចោទតាមរយៈការដាក់បណ្តឹង។ តុលាការអាចចាប់ផ្តើមធ្វើការជំនុំជម្រះបាន តែនៅពេលណាដែលទទួលបានពាក្យបណ្តឹងរបស់ដើមចោទប៉ុណ្ណោះ។

តុលាការមិនអាចចាប់ផ្ដើមនីតិវិធីនៃបណ្ដឹងបានឡើយ ប្រសិនបើពុំមានពាក្យបណ្ដឹងពីភាគីនោះ។ ម្យ៉ាងទៀត ជាគោលការណ៍ នៅពេលដែលមានការដាក់ពាក្យបណ្ដឹង ហើយការជំនុំជម្រះត្រូវបានចាប់ផ្ដើម ចំណុចដែលមានសរសេរនៅក្នុងពាក្យបណ្ដឹង ឬ ការទាម

ទារនៅក្នុងបណ្ដឹង អាចត្រូវបានជំនុំជម្រះ និងចេញសាលក្រម តែត្រឹមទំហំដែលបានសុំប៉ុណ្ណោះ។

ឧទាហរណ៍: ក្នុងករណីដែលដើមចោទប្ដឹងទារប្រាក់ចំនួន ៨ លានរៀល ក្នុចំណោម ១០ លានរៀល តុលាការមិនអាចចេញសាលក្រមបង្គាប់ឲ្យចុងចម្លើយសងប្រាក់លើសពី ៨

លានរៀលបានទេ បើទោះបីជាតុលាការយល់ឃើញថា ដើមចោទមានសិទ្ធិទាមទារប្រាក់រហូតដល់ ១០ លានរៀលក៏ដោយ ( មាត្រា ១៨២-២)។ នេះមានន័យថា ភាគីមានសិទ្ធិសម្រេចអំពីកម្មវត្ថុ និង ទំហំនៃការជំនុំជម្រះ និង ការចេញសាលក្រមនៅក្នុងបណ្តឹង។

ខ.ការបញ្ចប់បណ្តឹងដោយផ្អែកលើឆន្ទៈរបស់ភាគីម្ខាងទៀត ទោះបីជានីតិវិធីនៃបណ្តឹងត្រូវបានចាប់ផ្តើមហើយក៏ដោយ ដើមចោទអាចដកពាក្យបណ្តឹង និង បញ្ចប់បណ្តឹងបាន ( ប៉ុន្តែក្នុងករណីជាក់លាក់មួយចំនួន ចាំបាច់ត្រូវមានការយល់ព្រមពីចុងចម្លើយ ( សូមមើលមាត្រា ២១៧

កថាខ័ណ្ឌទី ១ ទី២ និង ២១៨។ លើសពីនេះទៀត ភាគីអាចបញ្ចប់បណ្តឹង ដោយមិនចាំបាច់រង់ចាំ សាលក្រមចុងក្រោយបាន តាមរយៈការលះបង់ ការទទួលស្គាល់នូវការទាមទារ ឬ តាមរយៈការ ផ្សះផ្សាលើបណ្តឹង (សូមមើល មាត្រា ២២០ , មាត្រា ២២១ )។

គ. គោលការណ៍នៃសិទ្ធិចាត់ចែងរបស់ភាគី និង មូលដ្ឋាននៃសិទ្ធិនេះ

ដូចពន្យល់ខាងលើ គោលការណ៍ដែល អនុញ្ញាតឲ្យភាគីធ្វើការសម្រេច (ការចាត់ចែង) ដោយផ្អែកលើឆន្ទៈរបស់ខ្លួន អំពីការចាប់ផ្តើម បណ្តឹង អំពីកម្មវត្ថុបណ្តឹង និងទំហំនៃការជំនុំ ជម្រះ និង ការចេញសាលក្រម និង ការបញ្ចប់

បណ្ដឹង គេហៅថា គោលការណ៍នៃសិទ្ធិចាត់ចែងរបស់ភាគី។

មូលដ្ឋាននៃការកំណត់យកគោលការណ៍នៃសិទ្ធិចាត់ចែង មកដាក់ក្នុងក្រមនីតិវិធីរដ្ឋប្បវេណីនេះ គឺដោយសារផ្អែកលើគោលការណ៍ស្វ័យភាពនៃបុគ្គលឯកជន។មានន័យថា សិទ្ធិ

ឬ ទំនាក់ទំនងគតិយុត្តិ ដែលជាកម្មវត្ថុនៃណ្ដឹងរដ្ឋប្បវេណី អាចត្រូវបានចាត់ចែងដោយសេរី ដោយផ្អែកតាមឆន្ទៈរបស់ភាគី។ ប្រសិនបើតុលាការដែលជាស្ថាប័នរដ្ឋ ចាប់ផ្ដើមបណ្ដឹង ហើយចេញសាលក្រម លើសពីទំហំដែលភាគីទាមទារ នោះត្រូវចាត់ទុកថា ជាការរំលោភ

បំពានទៅលើគោលការណ៍ស្វ័យភាពនៃបុគ្គល ឯកជន។ ប៉ុន្តែ ភាគីត្រូវតែអនុវត្តបណ្ដឹងដោយ ស្មោះត្រង់ និង សុចរិត (មាត្រា ៤)។ សកម្មភាព បណ្ដឹងដែលត្រូវបានចាត់ទុកថា មិនមានភាព ស្មោះត្រង់ ត្រូវកំណត់តាមករណីជាក់ស្ដែង នីមួយៗ។ នៅក្នុងក្រមនីតិវិធីរដ្ឋប្បវេណីមាន

បញ្ញត្តពាក់ព័ន្ធនឹងអានុភាពមិនអំណោយផលមួយ ចំនួនដែលកើតចេញពីការមិនគោរពកាតព្វកិច្ច អនុវត្តសកម្មភាពបណ្ដឹងដោយស្មោះត្រង់ និង សុចរិត ( មាត្រា ៩៤ មាត្រា ១៤០-២ មាត្រា ១៥៣ ជាដើម)

៤- ការចូលរួមរបស់តំណាងអយ្យការ

តំណាងអយ្យការគឺជាអ្នកតំណាងឲ្យផលប្រយោជន៍ សាធារណៈ ហេតុនេះហើយបានជាមានបញ្ញត្តិចែង ថា ក្នុងករណីដែលយល់ឃើញថា

ចាំបាច់ត្រូវការពារផលប្រយោជន៍សាធារណៈ តុលាការត្រូវជូនដំណឹងទៅតំណាងអយ្យការអំពីការទទួលពាក្យបណ្តឹងរដ្ឋប្បវេណី ( មាត្រា ៦ កថាខ័ណ្ឌទី ១ ទី ២)។

ការចូលរួមរបស់តំណាងអយ្យការត្រូវបានកម្រិតត្រឹមតែរឿងក្តីណាដែលមានភាពចាំបាច់

ត្រូវការពារផលប្រយោជន៍សាធារណៈប៉ុណ្ណោះ។ គួរកត់សំគាល់ថា នៅក្នុងករណីដែលភាគីជាអនិតិជន គឺអ្នកតំណាងដែលច្បាប់បានកំណត់ត្រូវដើរតួនាទីជាអ្នកការពារសិទ្ធិក្នុងនីតិវិធីរបស់ភាគី មិនមែនតំណាងអយ្យការទេ។

## ៥- គោលការណ៍ផ្សេងៗទៀតនៃការជម្រះក្តី

បន្ថែមពីលើគោលការណ៍នានាដែលបានរៀបរាប់ខាងលើ មានគោលការណ៍ផ្សេងៗ ជាច្រើនទៀត ពាក់ព័ន្ធទៅនឹងការជម្រះក្តី ដូចជា គោលការណ៍នៃការទាញហេតុផលផ្ទាល់មាត់ គោលការណ៍នៃការសម្រេចសេចក្តីដោយផ្អែកលើភស្តុតាង ជាដើមដែលគោលការណ៍ទាំងនេះនឹងមានពន្យល់នៅក្នុងផ្នែកនីមួយៗដែលពាក់ព័ន្ធ។



ដាក់បណ្ដឹង(៧៥)
តុលាការ
កាវិ.ក្រឡាបញ្ជី (៦១)
• ការពិនិត្យលើទម្រង់. ៧៨,
• អាចមានហេតុតាមមាត្រា ៨១, ៨២, ៨៣
ដីកាសម្រេចអំពីក្រុមប្រឹក្សា ឬ ចៅក្រម (២៣-៥)
ការកំណត់កាលបរិច្ឆេតត្រៀម (៨០-១)
ការបញ្ជូនពាក្យបណ្ដឹង (៧៩-១)
ការដាក់ឯកសារចម្លើយ (១០១)
និតិវិធីត្រៀម .. (៨០-១)
ការរៀបចំណុចវិវាទ (១០៣)
217
220
221
ការទាញហេតុផល ..
កាផ្សះផ្សារ (១០៤)
ដ/ចថ្លែងពីបណ្ដឹង និងច/ចថ្លែងពីឯកសារតប
កំណត់កាលបរិច្ឆេតត្រៀម ... បន្ទាប់
បង្គាប់ឱ្យដាក់ឯកសារត្រៀម (១០២)
ដ/ច និង ច/ច ថ្លែងពីឯកសារត្រៀម
សម្រេចតាមមាត្រា ៨៤, ៨៥, ៨៦, ៩៩, ១០០
ដីកាសម្រេចពិនិត្យភស្តុតាង (១០៦)
បញ្ជាក់នូវចំណុចត្រូវបំភ្លឺ (១០៧)
ការបញ្ចប់និតិវិធីត្រៀម... (១០៨)
កំណត់កាលបរិច្ឆេតនៃការទាញហេតុផល (១១៣)
កំណត់ហេតុនៃនិតិវិធីត្រៀម (១០៩)




ចប់
គោលការណ៍នានានៃក្រមនីតិវិធីរដ្ឋប្បវេណី

*សិស្សគួរចងចាំៈ* ប្លាតុង ទស្សនវិទូក្រិក
( ៤២៨-៣៤៧ មុនគ.ស.) បាននិយាយថាៈ

*ចំណេះវិជ្ជាក្លាយជាអាក្រក់ ប្រសិនបើ*

*គោលដៅរបស់វាគ្មានគុណធម៌។*

